ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខៈ......០៧៦......ប្រក.សក

រាជធានីភ្នំពេញ, ថ្ងៃទី....០១....ខែ....មីនា....ឆ្នាំ២០១៦

# ប្រកាស
## ស្តីពី
## ប្រតិភូកម្មមុខងារចុះបញ្ជីទោចក្រយានយន្ត ជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅតាមការិយាល័យច្រកចេញ-ចូលតែមួយ

## រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខនស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៧៧អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការចេញផ្លាកលេខសម្គាល់យានជំនិះ
- បានឃើញអនុក្រឹត្យលេខ ៦៨អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៨អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញសេចក្តីសម្រេចលេខ១២សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ របស់រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញប្រកាសរួមអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន
- យោងតាមការចាំបាច់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន

# សម្រេច

**ប្រការ១.-**

ធ្វើប្រតិភូកម្មមុខងារលើសេវាសាធារណៈចុះបញ្ជីផ្តល់បណ្ណសម្គាល់និងផ្លាកលេខទោចក្រយានយន្តទៅរដ្ឋបាលក្រុង ខណ្ឌ ស្រុក តាមការិយាល័យច្រកចេញ-ចូលតែមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រតិភូកម្មមុខងារ ដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវអនុវត្តតាមសេចក្តីណែនាំស្តីពីការអនុវត្តប្រកាសស្តីពីប្រតិភូកម្មមុខងារចុះបញ្ជីទោចក្រយានយន្តជូនរដ្ឋបាលក្រុង ខណ្ឌ ស្រុក នៅតាមការិយាល័យច្រកចេញ-ចូលតែមួយ។

**ប្រការ២.-**

មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត ត្រូវរៀបចំប្រតិភូកម្មមុខងារ និងមន្ត្រីជំនាញស្របតាមការចាំបាច់ក្នុងការផ្តល់សេវាសាធារណៈចុះបញ្ជីផ្តល់បណ្ណសម្គាល់និងផ្លាកលេខទោចក្រយានយន្តទៅរដ្ឋបាលក្រុង ខណ្ឌ ស្រុក តាមការិយាល័យច្រកចេញ-ចូលតែមួយ នៅក្នុងរង្វង់រាជធានី ខេត្តពាក់ព័ន្ធ។

មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត ត្រូវតាមដាន ត្រួតពិនិត្យ និងណែនាំការអនុវត្តប្រតិភូកម្មមុខងារដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើ។

**ប្រការ៣.-**

រដ្ឋបាលក្រុង ខណ្ឌ ស្រុក ត្រូវផ្តល់របាយការណ៍ពាក់ព័ន្ធនឹងស្ថិតិនៃការចុះបញ្ជីផ្តល់បណ្ណសម្គាល់និងផ្លាកលេខទោចក្រយានយន្តប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្តពាក់ព័ន្ធ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥.-**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- សាលារាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ